## ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ជម្រុញឲ្យបើកការស៊ើបអង្កេតលើការប៉ះទង្គិចគ្នារវាងកងកម្លាំងសន្តិសុខ និងក្រុមអ្នកតវ៉ា នៅប្រទេសកម្ពុជា



អ្នកនាំពាក្យនៃការិយាល័យ OHCHR កញ្ញា រ៉ាវីណា សំដាសានី ។ រូបថត: ពហុព័ត៌មាន អ.ស.ប

១៨ កក្កដា ២០១៤ – នៅថ្ងៃនេះ អង្គការសហប្រជាជាតិ បានឲ្យដឹងថា ខ្លួនមានកង្វល់ជាខ្លាំងអំពីការប៉ះទង្គិចគ្នាដែលបានផ្ទុះឡើងកាលពីដើមសប្តាហ៍នេះ នៅរាជធានីនៃប្រទេសកម្ពុជា រវាងកងកម្លាំងសន្តិសុខ និងអ្នកគាំទ្រគណបក្សប្រឆាំង ដែលក្នុងអំឡុងពេលនោះ មានមនុស្សរាប់សិបនាក់បានរងរបួស ហើយបានជម្រុញឲ្យបើកការស៊ើបអង្កេតលើករណីអំពើហិង្សានេះ។

សមាជិកគណបក្សប្រឆាំងដ៏ធំមួយ បានប្រមូលផ្តុំគ្នានៅសួនសេរីភាព រាជធានីភ្នំពេញ នៅថ្ងៃទី១៥ ខែកក្កដា ដើម្បីតវ៉ាប្រឆាំងនឹងដាក់បន្លាលួសព័ទ្ធជុំវិញទីតាំងតែមួយគត់ ដែលបានរៀបចំសម្រាប់ការធ្វើបាតុកម្មជាសាធារណៈនៅរាជធានីភ្នំពេញ នេះបើតាមព័ត៌មានពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR ) ។

" យើងមានការភ្ញាក់ផ្អើលជាខ្លាំង អំពីការចាប់ខ្លួនជាបន្តបន្ទាប់ នូវមេដឹកនាំគណបក្សសង្គ្រោះជាតិ បន្ទាប់ពីព្រឹត្តិការណ៍នៃអំពើហិង្សានេះ" អ្នកនាំពាក្យនៃការិយាល័យ OHCHR កញ្ញា រ៉ាវីណា សំដាសានី បានប្រាប់អ្នកយកព័ត៌មាននៅទីក្រុងហ្សឺណែវ ដូច្នេះ។

" យើងមានកង្វល់អំពីរាល់ការចោទប្រកាន់ធ្ងន់ធ្ងរប្រឆាំងនឹងពួកគេ រួមទាំងពីបទ "ការបះបោរ" បើទោះជាគេបានសង្កេតឃើញជាទូទៅ ពីការខិតខំប្រឹងប្រែងរបស់មេដឹកនាំគណបក្សប្រឆាំង ឲ្យក្រុមអ្នកតវ៉ារក្សាភាពស្ងប់ស្ងាត់ និងបញ្ឈប់អំពើហិង្សាក្នុងអំឡុងពេលនៃការប៉ះទង្គិចគ្នានោះក្តី។ ការចោទប្រកាន់ណាមួយ ដោយសារហេតុផលនយោបាយ ត្រូវតែទម្លាក់ចោលការចោទប្រកាន់នោះបន្ទាន់"។

ការិយាល័យ OHCHR បានអំពាវនាវឲ្យអាជ្ញាធរតុលាការ គោរពយ៉ាងហ្មឹងម៉ាត់តាមបទដ្ឋានសិទ្ធិមនុស្ស ក្នុងការដោះស្រាយករណីទាំងនេះ ដោយរំលឹកអំពីដំណើរការខុសឆ្គងធ្ងន់ធ្ងរជុំវិញករណីមួយចំនួន ដែលបានកើតមានកាលពីពេលថ្មីៗនេះ។

"យើងជម្រុញផងដែរ ឲ្យអាជ្ញាធរកម្ពុជា បើកការស៊ើបអង្កេតជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព មិនលំអៀង និងមានតម្លាភាព និងធ្វើឲ្យប្រាកដថា ជនដែលទទួលខុសត្រូវក្នុងឧប្បត្តិហេតុអំពើហិង្សាទាំងនេះ ត្រូវដាក់ឲ្យទទួលខុសត្រូវ" នេះបើតាមប្រសាសន៍របស់ កញ្ញា រ៉ាវីណា ។

ការិយាល័យOHCHR បានអំពាវនាវឲ្យភាគីទាំងអស់ អនុវត្តភាពអត់ធ្មត់ជាអតិបរមា និងបន្តការចរចាគ្នាតទៅទៀត ដើម្បីបញ្ចប់ភាពជាប់គាំងផ្នែកនយោបាយ និងបានសង្កត់ធ្ងន់ថា រាល់ការរិតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី ត្រូវតែបានដកចេញជាបន្ទាន់។

**ចប់**